**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**ខុមហ្វ្រែល COMFREL**

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

លោក **ធន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក **សុក សំអឿន**
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គហេរញ្ញិក
និង នាយក CCPCR

កញ្ញា **ស៊ុន ចាន់សែន**
Miss. SUN Chansen
ប្រធាន KYA

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

លោកស្រី **ពឹង យក់ហៀប**
Mr. PEUNG Yok Hiep
នាយិកា LAC

លោកស្រី **ទីវ សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា **សយ សារា វឌ្ឍនី**
Miss. SAY Sara Vathany
នាយិកា CWCC

លោក **គឹម សុវណ្ណ**
Mr. KIM Sovann
នាយក VIGILANCE

លោក **អាង ច័ន្ទឫទ្ធិ**
Mr. ANG Chanrith
នាយក KKKHRO

លោក **យង់ គិមអេង**
Mr. YONG Kim Eng
នាយក PDP-Center

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith

លោក **សេន សេត**
Mr. SEN Set

ស.ប្រ.ក.៧/លេខ ០៩/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[1] នៃវិស័យអាទិភាពក្នុង ខេត្ត កំពង់ធំ

*ភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩*

ម្ចាស់ឆ្នោតប្រមាណ ៨៣នាក់ មកពីស្រុកកំពង់ស្វាយ ស្រុកសន្ទុក ស្រុកប្រាសាទបល្ល័ង្គ និង ក្រុងស្ទឹងសែន ក្នុងខេត្តកំពង់ធំ និងមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ៥៣% បានជួបគ្នានៅថ្ងៃទី ១៧ មិថុនា ២០០៩ នៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ធំ ។

អភិបាលរងខេត្តកំពង់ធំ ឯកឧត្តម **គង់ វិមាន** បានថ្លែងវាយតម្លៃខ្ពស់ចំពោះគណៈកម្មាធិការខុមហ្វ្រែល ដែលបានរៀបចំសិក្ខាសាលានេះឡើងដើម្បីផ្តល់ឱកាសដល់ម្ចាស់ឆ្នោតធ្វើការបង្ហាញពីតម្រូវការរបស់ខ្លួនដល់មន្ត្រីជាប់ឆ្នោត ។

សមាជិកក្រុមប្រឹក្សាខេត្តកំពង់ធំ ឯកឧត្តម **កែវ ចំរើន** និងឯកឧត្តម **មុំ សារី** បានសន្យាថា គាំទ្រយកលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ លើកឡើងក្នុងប្រជុំវិសាមញ្ញក្តី ប្រជុំសាមញ្ញក្តី និងជំរុញដល់អាជ្ញាធរខេត្ត ឬអាជ្ញាធរស្រុក និងអាជ្ញាធរនៃរាជរដ្ឋាភិបាលឱ្យអនុវត្តឱ្យបានឆាប់រហ័ស ។ លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តកំពង់ធំរួមមានៈ

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអធិភាពនៅក្នុងខេត្ត កំពង់ធំ** |
| --- |
| ១) សុំអោយតុលាការកាត់ក្តីឱ្យមានយុត្តិធម៌ មិនលំអៀង មិនឱ្យមានអន្តរាគមន៍ ស៊ីសំណូក ស្របតាមការកំណត់នៃច្បាប់ ចាប់ពីឆ្នាំ ២០០៩ ព្រមទាំងអនុម័តច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឱ្យបាននៅត្រឹមឆ្នាំ ២០១០ ។ |

[1] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់ ។

| |
|---|
| ២) សុំឱ្យធ្វើការបណ្តុះបណ្តាលកសិករ ពីបច្ចេកទេសកសិកម្ម (ចិញ្ចឹមសត្វ-ធ្វើជីកំប៉ុស្តិ៍ ជីអ៊ីអឹម...) នៅទូទាំងខេត្តកំពង់ធំ ឱ្យបាន ៤ វគ្គ ក្នុងមួយឃុំ អោយបានគ្រប់ឃុំ ក្នុងមួយឆ្នាំ ចាប់ផ្តើមពីចុងឆ្នាំ ២០០៩ នេះតទៅ ។ |
| ៣) សុំឱ្យរដ្ឋាភិបាលផ្តល់ឥណទាន ដែលមានការប្រាក់ទាបជាង ៣% ក្នុងមួយឆ្នាំ សម្រាប់កសិករក្រីក្រក្នុងខេត្តកំពង់ធំ យកទៅប្រកប របរកសិកម្មចាប់ពីចុងឆ្នាំ ២០០៩ នេះតទៅ ។ |
| ៤) សុំផ្លូវ ៤ ខ្សែ ក្នុងស្រុកកំពង់ស្វាយ (១-ជួសជុលផ្លូវគ្រួសក្រហម និងក្រាលកៅស៊ូ តភ្ជាប់ ពីឃុំព្រៃគាហ្វ ដែលមានថ្នល់កៅស៊ូស្រាប់ តភ្ជាប់ទៅឃុំក្តីដូង និងភូមិពាមក្រែង-ចម្ងាយ ប្រហែល ៧ គីឡូម៉ែត្រ និងទទឹងប្រហែល ៨ ម៉ែត្រ យ៉ាងយូរបញ្ចប់ត្រឹមពាក់កណ្តាលឆ្នាំ ២០១០ ។ ២-សុំផ្លូវក្រាលគ្រួសក្រហម ពីមុខវត្តក្តីដូង ទៅមណ្ឌលសុខភាពគោកដូន —ចម្ងាយ ៣ គីឡូម៉ែត្រ និងទទឹង ប្រហែល ៨ ម៉ែត្រ យ៉ាងយូរបញ្ចប់ត្រឹមចុងឆ្នាំ ២០១០ ។ ៣-សុំផ្លូវក្រាលកៅស៊ូ ពីចុងភូមិកំពង់-ក្របៅ ទៅដល់ភូមិកំពង់ស្វាយ —ចម្ងាយ ១០ គីឡូម៉ែត្រ និងទទឹងប្រហែល ៨ម៉ែត្រ យ៉ាងយូរបញ្ចប់នៅចុងឆ្នាំ ២០១១ ។ ៤-សុំផ្លូវគ្រួសក្រហម ពីភូមិកូនត្នោត ទៅស្រុក ប្រាសាទសំបូរ ត្រូវការជួសជុល និងក្រាលកៅស៊ូ —ចម្ងាយប្រហែល ១៣ គីឡូម៉ែត្រ ចាប់ផ្តើមនៅដើមឆ្នាំ ២០១០ និងបញ្ចប់ត្រឹមចុងឆ្នាំ ២០១២ ។) |
| ៥) ជួយរកទីផ្សារជាតិ និងអន្តរជាតិ (ក្រុមហ៊ុន ឬសហគ្រាសក្នុងខេត្តកំពង់ធដើម្បីនាំចេញទៅកាន់ទីក្រុងភ្នំពេញ និងក្រៅប្រទេស) សម្រាប់ការលក់កសិផល (ស្រូវ សណ្តែកសៀង សណ្តែកបាយ ដំឡូងមី ពោត...) ចាប់ពីចុងឆ្នាំ ២០០៩ នេះតទៅ។ |
| ៦) ជំរុញឱ្យអនុម័តច្បាប់ប្រឆាំងអំពើពុករលួយឱ្យបាននៅដើមឆ្នាំ២០១០នឹងអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាពតាមគោលការណ៍នៃ ច្បាប់នេះ។ |
| ៧) ចាប់ពីដើមឆ្នាំ ២០១០ ដល់ ២០១៥ សុំឱ្យមានរោងចក្រកាត់ដេរក្នុងទីរួមខេត្តកំពង់ធំចំនួន ២ កន្លែង (ក្នុងមួយរោងចក្រប្រើប្រាស់ កម្លាំងពលកម្មពី ៥០០ ទៅ ២០០០ នាក់) ។ |
| ៨) បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញតម្បាញ ចម្លាក់ ។ល។ ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១១ ឱ្យមាន ២ កន្លែង ក្នុងទីរួមខេត្តកំពង់ធំ។ |
| ៩) កំណត់តម្លៃស្រូវឱ្យមានតម្លៃ (១ គីឡូក្រាម ស្រូវ = ១/៤ នៃតម្លៃសាំង ១ លីត្រ) ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១១ នៅក្នុងខេត្តកំពង់ធំ ។ |

លោក **យង់ គិមអេង** សមាជិកគណៈកម្មាធិការនាយកខុមហ្វ្រែល និងជាប្រធានមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីការអភិវឌ្ឍន៍ និងសន្តិភាព បានមានប្រសាសន៍ "របាយការណ៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពដែលម្ចាស់ឆ្នោតបានកំណត់នេះមានតម្លៃណាស់សម្រាប់យើងទាំងអស់គ្នា ក្នុងគោលបំណង បង្ហាញពីសេចក្តីត្រូវការរបស់ម្ចាស់ឆ្នោតក្នុងខេត្តកំពង់ធំ ដែលចង់ឱ្យគណបក្សនយោបាយ និងអាជ្ញាធរពាក់ព័ន្ធដោះស្រាយ។ យើងចង់ឃើញ លក្ខខណ្ឌសន្ទស្សន៍នេះ វាក្លាយជាការអនុវត្តជាក់ស្តែង ឈានទៅរកការប្រែប្រួលមុខមាត់ថ្មីនេះក្នុងខេត្តកំពង់ធំនេះជាចំបង" ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល ដោយមានកិច្ចសហការជាមួយ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា អង្គការអាដហុក អង្គការលីកាដូ អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារជនបទ និងអង្គការទ្រទ្រង់ស្ត្រីខ្មែរ ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ព្រៃឈើ ដីធ្លី... និងអង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត នៅតាមមណ្ឌលនីមួយៗៈ

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នក-តំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទងៈ*

- លោក **ចំនួ ជាវិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទៈ ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលស្ដីទីផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទៈ ០៨៩ ៥២៥ ៤៤៦